# សុន្ទរកថា

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីសម្ពោធបើកឱ្យប្រើប្រាស់ស្ពានតេជោមរកត (កោះពស់) ក្រោមទុនវិនិយោគ របស់ក្រុមហ៊ុនកោះពស់ ខេមបូឌា អ៊ិនវេសមេនគ្រុប អិលធីឌី

## ក្រុងព្រះសីហនុ ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១១

សូមក្រាបថ្វាយបង្គំ ៈ

- ព្រះតេជគុណ សសនៈ សំវរៈ **មូល រ៉ន** រាជាគណៈថ្នាក់កិត្តិយសព្រះមេគុណ ខេត្តព្រះសីហនុ
- ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ

សូមគោរព ៈ

- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត នៃប្រទេសជាមិត្ត ប្រចាំនៅកម្ពុជា
- លោក អាឡិកស៊ី ឈីប៉ា (Alexey CHEPA) ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុនកោះពស់
- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ
- បងប្អូនប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស ជាទីស្រឡាញ់ !

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយជាអតិបរិមា ដោយបានចូលរួមក្នុងពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការស្ពានកោះពស់ ដែលខ្ញុំបានឯកភាពតាមសំណើរបស់ក្រុមហ៊ុនវិនិយោគកោះពស់ឱ្យប្រសិទ្ធនាមជា **ស្ពានតេជោមរកត** ដែលសាងសង់ដោយទុនវិនិយោគរបស់ក្រុមហ៊ុនកោះពស់ ខេមបូឌា អិនវេសមិនគ្រុប អិលធីឌី ក្រោមការសម្របសម្រួលរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងសហការផ្នែកបច្ចេកទេសជាមួយក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រោមការត្រួតពិនិត្យបច្ចេកទេសដោយ

វិស្វករជនជាតិរុស្ស៊ីរបស់ក្រុមហ៊ុនកោះពស់។ ខ្ញុំព្រះករុណាខ្ញុំ នៅចាំបានថា កាលពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៨ ខ្ញុំក៏ត្រូវបានអញ្ជើញមកជាអធិបតីក្នុងពិធីបញ្ចុះបឋមសិលានៅទីនេះដែរ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងនូវការកោតសរសើរ រួមជាមួយនឹងអំណរគុណដ៏ជ្រាលជ្រៅចំពោះក្រុមហ៊ុនវិនិយោគកោះពស់ ដែលមានជំនឿជឿជាក់លើការដឹកនាំរបស់រាជរដ្ឋាភិបាល ដោយទោះបីបានឆ្លងកាត់កាលៈទេសៈដ៏លំបាក នៃវិបត្តិសេដ្ឋកិច្ចសកលលោកនាឆ្នាំ២០០៨-២០០៩ ក៏មិនបានរារែកក្នុងការអនុវត្តន៍គំរោងរបស់ខ្លួន ដោយបានចំណាយទុនវិនិយោគប្រមាណ ៥០លានដុល្លារអាមេរិករហូតដល់ថ្ងៃនេះ ដោយបានសាងសង់ស្ពាន និងបន្តការដ្ឋានទៅអភិវឌ្ឍន៍នៅលើកោះនេះឱ្យក្លាយជារមណីយដ្ឋាន និងជាមជ្ឈមណ្ឌលកំសាន្តលំដាប់អន្តរជាតិនៅតំបន់អាស៊ីអគ្នេយ៍។ ដំណើរការនៃគំរោងនេះ ឆ្លុះបញ្ចាំងប្រសិទ្ធភាពជាក់ស្តែង នៃចំណែកនៃការចូលរួមរបស់ផ្នែកឯកជនក្នុងការជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ហើយក៏ជាការឆ្លុះបញ្ចាំងភាពជឿជាក់របស់មជ្ឈដ្ឋានអន្តរជាតិលើស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម ក៏ដូចជាទៅលើការគាំទ្រការការពារ និងការលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលដល់វិនិយោគិននៅកម្ពុជា។ ករណីនេះក៏នឹងអាចជួយទាក់ទាញបន្ថែមនូវការវិនិយោគដទៃទៀតទៅថ្ងៃអនាគតផងដែរ។

ខ្ញុំព្រះករុណាខ្ញុំ សូមអបអរសាទរ និងថ្លែងនូវការកោតសរសើរចំពោះក្រុមហ៊ុនសំណង់សាជីវកម្ម ស៊ីណូហីដ្រូ នៃសាធារណរដ្ឋប្រជាមានិតចិន និងអ្នកត្រួតពិនិត្យបច្ចេកទេសសំណង់ជនជាតិរុស្ស៊ី ដែលបានខិតខំសាងសង់ស្ពាននេះ រហូតសំរេចជោគជ័យប្រកបដោយសោភ័ណភាព គុណភាព និងប្រសិទ្ធភាពប្រើប្រាស់។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃក្រសួងសាធារណៈការ និងដឹកជញ្ជូន ដែលបានផ្តល់ការគាំទ្រ និងកិច្ចសហការដែលបានធានាជោគជ័យនៃសមិទ្ធផលដ៏ធំធេងនេះ។

ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី!

នៅពេលនេះ **ស្ពានគេះខោមរភគ** ដែលតភ្ជាប់ឆ្នេរក្រុងព្រះសីហនុ ទៅកោះពស់បានសាងសង់ជាស្ថាពររួចហើយ។ ជំហានបន្ទាប់ ក្រុមហ៊ុននឹងធ្វើការសាងសង់ផ្លូវក្រវ៉ាត់នៅលើកោះ មុន

នឹងចាប់ផ្តើមធ្វើការសាងសង់លំនៅដ្ឋាន និងអគារនានានៃមជ្ឈមណ្ឌលទេសចរណ៍។ គំរោងនេះជាគំរោងវិនិយោគខ្នាតធំដែលឈានមុខជាងគេ នៅក្នុងចំណោមគំរោងដទៃទៀតនៅតាមបណ្តាឆ្នេរ និងកោះនានាដែលរាជរដ្ឋាភិបាលបានអនុម័ត។ នៅឆ្នាំ២០០៩ ខ្ញុំបានសំរេចបង្កើតក្រុមការងារពិសេសដើម្បីសម្របសម្រួល និងជំរុញការដោះស្រាយបញ្ហាពាក់ព័ន្ធ និងដំណើរការគំរោងអភិវឌ្ឍកោះពស់ និងផ្នែកនៃតំបន់ឆ្នេរហាវ៉ៃ ដែលដឹកនាំដោយអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមានរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប ជាអនុប្រធាន និងមានតំណាងក្រសួងពាក់ព័ន្ធមួយចំនួន ព្រមទាំងអភិបាលខេត្តព្រះសីហនុ ជាសមាជិក។ ទន្ទឹមនឹងការដោះស្រាយរាល់បញ្ហាដែលក្រុមហ៊ុនវិនិយោគកោះពស់ ជួបប្រទះក្នុងដំណើរការអភិវឌ្ឍន៍គំរោង ការបង្កើតក្រុមការងារពិសេសនេះ ផ្តល់ផលប្រយោជន៍មួយទៀត គឺការដកស្រង់មេរៀនក្នុងការដោះស្រាយបញ្ហា ដើម្បីយកបទពិសោធន៍ទាំងនេះយកទៅអនុវត្ត នៅតាមបណ្តាគំរោងដទៃទៀត នៅតាមបណ្តាកោះ និងឆ្នេរ។ យើងត្រូវទទួលស្គាល់ថា ចំពោះក្រសួងពាក់ព័ន្ធ កិច្ចការទាំងនេះ ជាកិច្ចការពុំទាន់ដែលបានជួបប្រទះ។ ខ្ញុំសង្ឃឹមថា ដោយសារសភាពការសេដ្ឋកិច្ចបានមានការល្អប្រសើរឡើងវិញ បន្ទាប់ពីកលយុគហិរញ្ញវត្ថុឆ្នាំ២០០៨-២០០៩ ក្រុមហ៊ុនអភិវឌ្ឍន៍គំរោងដទៃទៀត នឹងខិតខំចាប់ផ្តើមអនុវត្តគំរោងរបស់ខ្លួន ឬបង្កើនល្បឿននៃការអនុវត្តន៍គំរោង។ ខេត្តព្រះសីហនុ និងតំបន់ឆ្នេរ ត្រូវបានចាត់ទុកថា ជាប៉ូលសេដ្ឋកិច្ចទី៣ បន្ទាប់ពីប៉ូលរាជធានីភ្នំពេញ និងប៉ូលទេសចរណ៍ខេត្តសៀមរាប។ នៅថ្ងៃខាងមុខ យើងនឹងអភិវឌ្ឍន៍ប៉ូលទី៤មួយទៀត គឺភូមិភាគឥសាននៃកម្ពុជា ដែលមានសក្តានុពលក្នុងវិស័យអេកូទេសចរណ៍ កសិ-ឧស្សាហកម្ម និងវិស័យអាជីវកម្មធនធានរ៉ែ។ កាលពីរសៀលថ្ងៃទី ១១ ខែកក្កដាម្សិលមិញនេះ នៅក្រុងព្រះសីហនុនេះដែរ យើងបានអបអរសាទរការដាក់បញ្ចូលឆ្នេរសមុទ្រកម្ពុជា ជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក។ នៅក្នុងពិធីនោះ ខ្ញុំបានដាក់ចេញនូវអនុសាសន៍គន្លឹះចំនួន៨ ដើម្បីជំរុញដំណើរការគ្រប់គ្រង និងអភិវឌ្ឍន៍ឆ្នេរសមុទ្រកម្ពុជា ប្រកបដោយនិរន្តភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ សក្តិសមជាសមាជិកនៃក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក ដែលអនុសាសន៍ទាំងនោះផ្តោតភាគច្រើនលើការកសាងក្របខណ្ឌ និងបទដ្ឋាន

គតិយុត្ត។ នៅពេលនេះ ខ្ញុំសូមដាក់ចេញនូវអនុសាសន៍មួយចំនួនទៀត ដើម្បីផ្ដល់ការណែនាំដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធអនុវត្តជាបន្ទាន់ ដើម្បីជំរុញសកម្មភាពគាំទ្រការអភិវឌ្ឍន៍ទៅថ្ងៃខាងមុខ និងដើម្បីរក្សាវត្តមានរបស់ឆ្នេរកម្ពុជានៅក្នុងក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក។ អាចនិយាយមួយបែបទៀតថា បានចូលជាសមាជិកហើយជាការល្អ តែបន្តស្ថិតជាសមាជិកនៅអនាគតខាងមុខជាការប្រសើរ។

ក្នុងរយៈពេល១៦ខែ ចាប់ពីខែមីនា ឆ្នាំ២០០៩ ដល់ខែកញ្ញា ឆ្នាំ២០១០ គណៈកម្មាធិការអន្តរក្រសួងមួយក្រោមការដឹកនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានសហការជាមួយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) នៃប្រទេសជប៉ុន ដើម្បីធ្វើការសិក្សាស្ដីពីយុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរ និងប្លង់គោលក្រុងព្រះសីហនុសំរាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ថ្វីត្បិតនៅពេលនេះ យុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរ និងប្លង់គោលក្រុងព្រះសីហនុ សំរាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព មិនទាន់បានដាក់ឆ្លងការពិនិត្យ និងអនុម័តពីអង្គគណៈរដ្ឋមន្ត្រីក៏ដោយ ក៏យើងអាចចាត់វិធានការមួយចំនួន ដែលផ្អែកទៅលើគំហើញនៃការសិក្សា។

ក្នុងន័យនេះ ខ្ញុំសូមក្រសួង-ស្ថាប័នពាក់ព័ន្ធខាងក្រោម ចាត់វិធានការដូចតទៅ ៖

ទី១- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវរួសរាន់រៀបចំដាក់ជូនរាជរដ្ឋាភិបាលសម្រេចដាក់អោយប្រើប្រាស់ជាផ្លូវការនូវគំរោងយុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរ និងផែនការរៀបចំដែនដីខេត្តព្រះសីហនុសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ជាការពិត ខ្ញុំបានលើកករណីនេះពីម្សិលមិញម្ដងហើយ។ ការអនុម័តរបស់រាជរដ្ឋាភិបាល នឹងបញ្ជូនសារលើកទឹកចិត្តវិនិយោគិនអោយបង្កើនល្បឿននៃការអនុវត្តន៍គំរោងរបស់ខ្លួន និងទាក់ទាញវិនិយោគថ្មីបន្ថែមទៀត ទាំងក្នុងវិស័យទេសចរណ៍ ពាណិជ្ជកម្ម ឧស្សាហកម្ម និងកសិកម្ម។ ម្យ៉ាងវិញទៀត បន្ទាប់ពីការអនុម័តជាផ្លូវការ ក្រសួង-ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន នឹងមានការងាយស្រួលក្នុងការអនុវត្តន៍ភារកិច្ចរៀង១ខ្លួនដោយស្មារតីទទួលខុសត្រូវ។

ទី២- ចំពោះមុខ ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ យើងអាចចាត់ទុកថា ផ្នែកផ្គត់ផ្គង់ថាមពលអគ្គិសនីនឹងមិនចោទជាបញ្ហាទេ។ នៅបំណាច់ឆ្នាំ២០១១ គំរោងវារីអគ្គិសនីកំចាយ ដែលមានកំលាំង ១៩៣មេហ្គាវ៉ាត់ នឹងចូលដំណើរការនៅដើមឆ្នាំ២០១២ គំរោងវារីអគ្គិសនីគីរីរម្យ៣ កំលាំង ១៨មេហ្គាវ៉ាត់ ស្ថិតនៅស្រែអំបិលនឹងចូលដំណើរការ និងជាបន្តបន្ទាប់ គំរោងវារីអគ្គិសនីតាតៃ កំលាំង ២៤៦មេហ្គាវ៉ាត់ គំរោងវារីអគ្គិសនីឫស្សីជ្រុំក្រោម កំលាំង ៣៣៨មេហ្គាវ៉ាត់ និងគំរោងវារីអគ្គិសនីស្ទឹងអាតៃ កំលាំង១២០មេហ្គាវ៉ាត់នឹងចូលដំណើរការ។ ដូចគ្នានេះដែរ គំរោងផលិតអគ្គិសនីដោយធ្យូងថ្មនៅក្រុងព្រះសីហនុ កំលាំង ១០០មេហ្គាវ៉ាត់ នឹងចូលដំណើរការនៅត្រីមាសទី១ ឆ្នាំ២០១៣។ ការព្រួយបារម្ភរបស់ខ្ញុំផ្តោតទៅលើការផ្គត់ផ្គង់ទឹកស្អាត។ យើងចាំបានថា នៅឆ្នាំ២០០៧ ក្នុងមួយរយៈ ទីក្រុងព្រះសីហនុបានជួបប្រទះកង្វះខាតទឹកស្អាត។ តាមការសិក្សាស្រាវជ្រាវកន្លងទៅក៏យើងបានដឹងថា ការផ្គត់ផ្គង់ទឹកស្អាតជាការប្រឈម ក្នុងការអភិវឌ្ឍន៍ក្រុងព្រះសីហនុ។ យ៉ាងណាមិញ រាជរដ្ឋាភិបាលបានមានវិធានការតឹងរ៉ឹង ដើម្បីរក្សាប្រភពទឹកនៅតំបន់ក្បាលឆាយ រួចហើយ។ កាលពីថ្ងៃសៅរ៍ ទី៩ ខែកក្កដា ឆ្នាំ២០១១ គឺបីថ្ងៃមុននេះ ខ្ញុំបានទទួលរបាយការណ៍របស់ឯកឧត្តម អឹម ឈុនលឹម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីលទ្ធផលប្រជុំពិភាក្សារវាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងសាលាខេត្តព្រះសីហនុ លើករណីសំណើរបស់ប្រជាពលរដ្ឋចំនួន ៥១គ្រួសារ សុំចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុក្នុងតំបន់បឹងព្រែកទប់ ស្ថិតនៅភូមិទី១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ បច្ចុប្បន្ន តំបន់បឹងព្រែកទប់មានទំហំ ៨២ហិកតា ចែកជាផ្ទៃបឹង១៤ហិកតា និងផ្ទៃរងទឹកភ្លៀង ៦៨ហិកតា។ លើផ្ទៃរងទឹកភ្លៀងមាន ការកាន់កាប់ដីប្រមាណ២៣០ក្បាលដី ចែកចេញជា ៣ ប្រភេទ ក្នុងនេះមានក្បាលដីរបស់ប្រជាពលរដ្ឋ ៥១គ្រួសារ ដែលបានធ្វើសំណើសុំអន្តរាគមន៍ពីខ្ញុំ ស្មើនឹង១១០ក្បាលដី មានទំហំ ១៧,២៨ហិកតា។ យើងត្រូវតែរក្សាអោយបានប្រភពទឹកបឹងព្រែកទប់ តែពុំអាចរក្សាផ្ទៃរងទឹកភ្លៀង ៦៨ហិកតា បានទេ។ ដូច្នេះ ខ្ញុំបានសម្រេចអោយកាត់បន្ថយផ្ទៃរងទឹកភ្លៀងមកត្រឹម ៤៤ហិកតា (រួមទាំងផ្ទៃបឹង ១៤ហិកតា សរុបបានផ្ទៃប្រភពទឹក

៥៨ហិកតា)។ ចំពោះផ្ទៃដីរងទឹក ភ្លៀង២៤ហិកតា ដែលបានកាត់ចេញត្រូវរៀបចំផែនការប្រើប្រាស់ដីប្រមូលផ្តុំតាមបណ្តោយដង វិថី២ធ្នូ វិថីសន្តិភាព និងតាមរបងវត្តឥន្ទញ្ញាណ ដែលមានហេដ្ឋារចនាសម្ព័ន្ធស្រាប់សរុបប្រវែង ២,៥គីឡូម៉ែត្រ និងអាចយកជំរៅដី១00ម៉ែត្រពីមាត់ផ្លូវដែលមួយផ្នែកនៃដី ២៤ហិកតានេះ នឹងត្រូវរៀបចំធ្វើការបែងចែកជូនបងប្អូនប្រជាជន ដែលរស់នៅទីនោះ ដោយផ្តល់សិទ្ធិកម្មសិទ្ធិលើដី ដែលបានទទួលជាផ្ទូរ។ វិធានការដោះស្រាយនេះជាការអនុវត្តនយោបាយឈ្នះ-ឈ្នះ ដែលផ្តល់នូវភាពអំណោយផលដល់អ្នកកាន់កាប់ដីដោយខុសច្បាប់បច្ចុប្បន្នផង និងដល់រដ្ឋផងដែរគឺ ១)- ប្រជាពលរដ្ឋបានទទួលសិទ្ធិកម្មសិទ្ធិលើដីដែលបានទទួលជាផ្ទូរ ២)- ប្រជាពលរដ្ឋបានរស់នៅលើ ទីតាំង ដែលមានការរៀបរយ និងនៅជាប់នឹងផ្លូវសាធារណៈ ហើយអាចសាងសង់លំនៅដ្ឋានសំរាប់ស្នាក់នៅ ឬសំរាប់ធ្វើអាជីវកម្មបានទៀតផង។ ចំពោះរដ្ឋ គឺបានរក្សាប្រភពទឹកសាបនៃបឹង ព្រែកទប់ ក្នុងទំហំមួយធំជាបង្គួរ ដែលអាចផ្តល់លទ្ធភាពពង្រីកផ្ទៃបឹងនេះទៅអនាគត ទន្ទឹមនេះ ក៏ដោះស្រាយបានសំណង់អាណាធិបតេយ្យ ព្រមទាំងកែលម្អបានស្ថានភាពនគរូបនីយកម្មរបស់ ក្រុងព្រះសីហនុ។ ចំពោះយន្តការដោះស្រាយវិធានការខាងលើ ត្រូវអនុវត្តតាមនីតិវិធីនៃសារាចរ លេខ 0៣ ចុះថ្ងៃទី៣១ខែឧសភា ឆ្នាំ២០១០ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន។ បឹងព្រែកទប់ និងក្បាលឆាយជាប្រភពទឹកសាប ២កន្លែងពុំអាចខ្វះបានសំរាប់ផ្គត់ផ្គង់ក្រុងព្រះសីហនុ។ ការពិតសេចក្តីត្រូវការទឹកសាបរបស់ក្រុងព្រះសីហនុនាពេលអនាគត នឹងកាន់តែមានទំហំច្រើន ដោយទីក្រុងនេះនឹងរីកធំឡើងពុំអាចស្មានបាន ដោយការរីកលូតលាស់នៃវិស័យទេសចរណ៍ និងនៃតំបន់សេដ្ឋកិច្ចពិសេសគួបផ្សំនឹងពេលចាប់ដំណើរការអាជីវកម្មប្រេង ក្រៅពីនេះ រោងចក្រធំៗ ដូចជា រោងចក្រអគ្គិសនីប្រើថាមពលធ្យូងថ្ម នាវាសមុទ្រធំៗ ក៏សុទ្ធតែត្រូវការការផ្គត់ផ្គង់ទឹក សាបផងដែរ។

ទី៣- នៅថ្ងៃខាងមុខ ស្របតាមល្បឿននៃការរីកលូតលាស់នៃសេដ្ឋកិច្ចរបស់ខេត្តព្រះសីហនុ ទាំងក្នុងវិស័យទេសចរណ៍ ទាំងក្នុងវិស័យឧស្សាហកម្ម នឹងមានកំណើននៃតំរូវការនៃការផ្គត់ផ្គង់ស្បៀងអាហារ។ ដូចនេះ ខ្ញុំសូមអោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការគិតគូរ

រៀបចំគំរោងខ្សែរក្រវ៉ាត់បៃតងនៅខេត្តព្រះសីហនុ ដូចលំនាំខ្សែរក្រវ៉ាត់បៃតងដែលយើងមាននៅខេត្តសៀមរាប ដើម្បីបញ្ចូលទៅក្នុងប្លង់គោលក្រុងព្រះសីហនុ។ ទន្ទឹមនឹងនេះដែរ ខ្ញុំសូមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជំរុញលើកទឹកចិត្តបងប្អូនប្រជាជនមូលដ្ឋាន ពង្រីកសកម្មភាពរបស់ខ្លួនក្នុងវិស័យវារីវប្បកម្ម ព្រោះនៅថ្ងៃខាងមុខ យើងមិនអាចរំពឹងលើមច្ឆាជាតិដែលចាប់ពីទឹកសមុទ្ររបស់យើង។ ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណចំពោះរដ្ឋាភិបាលជប៉ុនដែលបានផ្តល់ជំនួយឥតសំណងចំនួន ៩៣១លានយ៉េន ស្មើនឹង ១១,៤៥លានដុល្លារអាមេរិកសំរាប់សាងសង់មជ្ឈមណ្ឌលវារីវប្បកម្មសមុទ្រ។ ជាការពិតហើយ ដំណាំកសិកម្ម ជាបន្លែ ផ្លែឈើ និងការចិញ្ចឹមត្រី បង្គារ ក្តាម អាចបំរើការនាំចេញ ក៏ដូចជាបំរើតំរូវការទេសចរដែលមកកំសាន្តនៅតំបន់ឆ្នេរ ដោយការផ្គត់ផ្គង់នេះ អាចចាត់ទុកជាការនាំចេញនៅនឹងកន្លែង។

ទី៤- ជាមួយគ្នានេះដែរ ភ្ញៀវទេសចរតែងតែចង់ទិញសិប្បកម្មវត្ថុអនុស្សាវរីយ៍នៃតំបន់ដែលខ្លួនទស្សនាកំសាន្ត ដូចនេះ ត្រូវជំរុញសកម្មភាពចលនាភូមិមួយផលិតផលមួយអោយបានកាន់តែផុសផុលថែមទៀត។

ទី៥- យោងតាមការព្យាករណ៍នៃការអភិវឌ្ឍន៍ខេត្តព្រះសីហនុ ក៏ដូចជាតំបន់ឆ្នេរ ទាំងក្នុងវិស័យទេសចរណ៍ ទាំងក្នុងវិស័យឧស្សាហកម្មដែលនឹងបង្កើតការងាររាប់ម៉ឺនកន្លែងជូនបងប្អូនយើង ខ្ញុំសូមអោយគណៈកម្មាធិការជាតិបណ្តុះបណ្តាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងទេសចរណ៍ និងក្រសួងសុខាភិបាល មានវិធានការចាប់ពីពេលនេះ ដើម្បីនៅពេលខាងមុខដ៏ខ្លី ជៀសវាងកុំអោយការអភិវឌ្ឍន៍ជួបប្រទះកង្វះខាតកំលាំងពលករ ដូចជា ជាងសំណង់ ជាងភ្លើង ជាងផ្សារ ជាងឈើ បុគ្គលិកបំរើសេវាទេសចរណ៍តាមភោជនីយដ្ឋាន សណ្ឋាគារ គិលានុបដ្ឋាយិការ។ល។ ពាក់ព័ន្ធនឹងការបង្កើតការងារជូនបងប្អូនរស់នៅខេត្តព្រះសីហនុ ក៏ដូចជាបងប្អូនមកពីខេត្តដទៃទៀត ខ្ញុំក៏សូមអំពាវនាវអោយគំរោងវិនិយោគវិស័យទេសចរណ៍ ទទួលយុវជនកម្ពុជា ដែលជានិស្សិត វិស្វករ និងអ្នកបច្ចេកទេសនានា អោយមកចូលរួមក្នុងការដ្ឋានរបស់ខ្លួន ដើម្បីទទួលការផ្ទេរចំណេះដឹង និងចំណេះធ្វើពីវិស្វករ និងអ្នកជំនាញបរទេស។

ទី៦- ជាចំណុចចុងក្រោយ ខ្ញុំសូមអោយគ្រប់ក្រសួង-ស្ថាប័ន យកចិត្តទុកដាក់ជាទីបំផុត ទៅលើការការពារ និងថែរក្សាបរិស្ថាន និយាយអោយចំត្រូវលុបបំបាត់អោយបាននូវភាពកខ្វក់ ដែលបច្ចុប្បន្នយើងជួបប្រទះជារៀងរាល់ថ្ងៃនៅតាមបណ្តាឆ្នេរ និងកោះ។ អាជ្ញាធរខេត្ត ព្រះសីហនុ ក្រសួងបរិស្ថាន និងក្រសួងទេសចរណ៍ត្រូវបង្កើនការផ្សព្វផ្សាយ ការអប់រំ ការលើកកម្ពស់ស្មារតីមោទនភាពជាតិ ដើម្បីបញ្ឈប់នូវទម្លាប់ចោលរាយប៉ាយស្បោងកៅស៊ូ កំប៉ុង ដបជ័រ និងកាកសំណល់គ្រប់ប្រភេទ តាមទីធ្លាសារធារណៈ ក៏ដូចជាការចោលនៅក្នុងសមុទ្រ។ ការគ្រប់គ្រងទាំងសំណល់រឹង ទាំងសំណល់រាវជាកាតព្វកិច្ចទី១ ដើម្បីធានាវត្តមានឆ្នេរកម្ពុជានៅក្នុង ជួរសមាជិកក្លិបឆ្នេរសមុទ្រដែលស្អាតជាងគេបំផុតលើសកលលោកនៅពេលអនាគត។ តាម ពតិមានដែលទទួលបាន នៅលើឆ្នេរកោះពស់ជារៀងរាល់ថ្ងៃ ក្រុមហ៊ុនត្រូវប្រមូលបោសសំអាត កាកសំរាមរាប់សិបគីឡូដែលរសាត់តាមទឹក និងដែលរលកបោកបក់មកលើឆ្នេរ។ ពាក់ព័ន្ធនឹងការ គ្រប់គ្រងកាកសំណល់រឹង អាជ្ញាធរខេត្តព្រះសីហនុបានផ្លាស់ទីតាំងកន្លែងចាក់សំរាម ពីទីតាំងស្ថិត នៅជាប់តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ឃុំបិតត្រាំង ទៅទីតាំងថ្មីដែលមានចំងាយ ៣០គ.ម ពីក្រុងព្រះសីហនុ នៅចំណុចអូឧកញ៉ាហេង នៅតាមដងផ្លូវជាតិលេខ៤។ ពាក់ព័ន្ធនឹងប្រព័ន្ធបង្ហូរ សំណល់រាវ អាជ្ញាធរខេត្តព្រះសីហនុត្រូវធ្វើការគិតគូអោយបានគ្រប់ជ្រុងជ្រោយ ព្រោះនៅពេល បច្ចុប្បន្ន ការបង្ហូរទឹកកខ្វក់ចូលសមុទ្រដោយផ្ទាល់ ដោយមិនឆ្លងកាត់អាងចំរោះនៅអូឈើទាល មានកំរិតខ្ពស់។ ខ្ញុំសង្ឃឹមថា ការអនុម័តប្លង់គោលក្រុងព្រះសីហនុ នឹងអាចលើកទឹកចិត្តអោយ ដៃគូអភិវឌ្ឍន៍ ក៏ដូចផ្នែកឯកជនចូលរួមដោះស្រាយបញ្ហានេះ ក្រោមរូបភាពសម្បទាន BOT ។

ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី!

កម្ពុជា ក្នុងវិស័យទេសចរណ៍ មានសំណាងដោយមានប្រាង្គប្រាសាទបេតិកភ័ណ្ឌជាតិនៅ តំបន់សៀមរាបអង្គរ ព្រះវិហារ ក៏ដូចនៅតាមបណ្តាខេត្តមួយចំនួនទៀត ទន្ទឹមនឹងនេះ កម្ពុជា មានព្រៃព្រឹក្សា បឹងទន្លេ ឆ្នេរសមុទ្រដ៏ល្អស្អាត ដែលសំបូរដោយប្រព័ន្ធជីវៈចំរុះ។ លើសពីនេះទៅ ទៀត ប្រទេសកម្ពុជាមិនស្ថិតនៅក្នុងតំបន់ដែលត្រូវរងគ្រោះមហន្តរាយដ៏ឃោរឃៅ ដូចជា ព្យុះ សង្ឃរា ការរញ្ជួយផែនដី រលកយក្សស៊ូណាមិ ដែលកត្តាទាំងនេះផ្តល់លទ្ធភាពអោយកម្ពុជា និយាយជា

រួម និងតំបន់ឆ្នេរ និងតំបន់កោះ និយាយដោយឡែក មានកាលានុវត្តភាពដ៏ធំធេងក្នុងការអភិវឌ្ឍន៍វិស័យទេសចរណ៍។ តួនាទីរបស់រាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ ព្រមទាំងប្រជាជនគ្រប់រូប ត្រូវថែរក្សាទ្រព្យសម្បត្តិធម្មជាតិ និងវប្បធម៌របស់កម្ពុជា។ ខ្ញុំសង្ឃឹមថា អនុសាសន៍ទាំងប៉ុន្មានខាងលើនេះ នឹងជំរុញជាមិនខាន ការអភិវឌ្ឍន៍ទីក្រុងព្រះសីហនុ និងតំបន់ឆ្នេរ និងកោះរបស់យើង ដើម្បីចូលរួមយ៉ាងពេញទំហឹងក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមនៃប្រទេសជាតិ។ យើងត្រូវដឹងថា ឆ្នេរកម្ពុជាមានការប្រកួតប្រជែងជាមួយរមណីយដ្ឋានមជ្ឈមណ្ឌលទេសចរណ៍តាមឆ្នេរនៃប្រទេសក្នុងតំបន់ តែកម្ពុជាដោយស្មារតីសហការ និងទទួលខុសត្រូវ នឹងទទួលជោគជ័យក្នុងកិច្ចការអភិវឌ្ឍន៍តំបន់ឆ្នេរប្រកបដោយចីរភាពជាមិនខាន។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមប្រសិទ្ធពរជូនឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ និងបងប្អូនមន្ត្រីរាជការ និយោជិត និងប្រជាពលរដ្ឋទាំងអស់ សូមទទួលពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបើកឱ្យប្រើប្រាស់ជាផ្លូវការ **ស្ពានគេះខៅមរកត** ពីឆ្នេរហាវ៉ៃឆ្ពោះទៅកាន់កោះពស់ នៃក្រុងព្រះសីហនុ ចាប់ពីពេលនេះតទៅ !

**សូមអរព្រះគុណ និង សូមអរគុណ !**